KBrief
សេចក្តីសង្ខេបការផ្លាស់ប្តូរបទពិសោធន៍
PREM

# កម្ពុជាៈ ការវាយតំលៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញលើចំណាយសាធារណៈ ~ ការលើកកំពស់ការផ្គត់ផ្គង់សេវា

ការវាយតំលៃចំរុះលើទំនុកចិត្ត និងការពិនិត្យសើរើឡើងវិញលើចំណាយសាធារណ (IFAPER) នេះ ត្រូវបានចាប់ផ្តើមរាយការណ៍ជូនទាំងកម្មវិធីកំណែទំរង់យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ (NPRS) និងទាំងកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ (PEM) ដែលកំពុងត្រូវបានរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា (RGC)។ ចាប់តាំងពីមានការពិនិត្យសើរើឡើងវិញជាចុងក្រោយលើចំណាយសាធារណក្នុងឆ្នាំ ១៩៩៩ មក ប្រទេសកម្ពុជាបានមានការអភិវឌ្ឍខ្លះលើការកែទំរង់គោលនយោបាយនិងការគ្រប់គ្រងចំណាយសាធារណៈ។

ក៏ប៉ុន្តែ អត្រានៃប្រាក់ចំណូលសារពើពន្ធរបស់កម្ពុជា ជាពិសេសប្រាក់ចំណូលពន្ធដា នៅតែមានកំរិតទាបជាងគេបំផុតនៅក្នុងពិភពលោក។ លើសពីនេះទៀត គេមើលឃើញកាន់តែច្បាស់ថា ភាពទន់ខ្សោយនៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណមិនត្រឹមតែមានកំរិតខ្ពស់លើប្រសិទ្ធិភាពបែងចែកនិងប្រតិបត្តិប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបង្កើតនូវកំរិតហានិភ័យនៃទំនុកចិត្តមានកំរិតខ្ពស់ដែលមិនអាចទទួលយកបានចំពោះមូលនិធិសាធារណ។

IFAPER ផ្តល់នូវការវាយតំលៃលើទំនុកចិត្តនិងការវាយតំលៃចំរុះលើការគ្រប់គ្រងចំណាយ ដែលបានធ្វើឡើងក្នុងភាពជាដៃគូជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ IFAPER គឺជាការផ្សព្វផ្សាយរួមលើកដំបូងរបស់ធនាគារពិភពលោកនិងធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងប្រទេសកម្ពុជា។ ការអនុវត្តអនុសាសន៍សំខាន់ៗរបស់ខ្លួនត្រូវបានគាំទ្រដោយភាពជាដៃគូថ្មីមួយរបស់ម្ចាស់ជំនួយជាច្រើនសំរាប់ជំនួយបច្ចេកទេស (ផ្អែកលើវិធីសាស្រ្តទូទាំងវិស័យ) ដោយផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាព។

## លទ្ធផល និងអនុសាសន៍

ចាប់តាំងពីឆ្នាំ ១៩៩៨ មក រដ្ឋាភិបាលបានកែលំអយ៉ាងគួរអោយកត់សំគាល់លើការរៀបចំធនធាន ជាមួយនិងទិសដៅអភិវឌ្ឍន៍របស់ខ្លួន តាមរយៈការបង្កើនការបែងចែកសំរាប់វិស័យអាទិភាពនានា ជាពិសេសលើវិស័យអប់រំនិងសុខាភិបាល។ ក៏ប៉ុន្តែ ដើម្បីអនុវត្ត NPRS និងដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា វានឹងចាំបាច់ដើម្បីធ្វើអោយមានការរីកចំរើនបន្ថែម។ ជាពិសេស វានឹងត្រូវការចាំបាច់ដើម្បី (ក) កែលំអការកៀងគរធនធានដើម្បីធានាដល់និរន្តរភាពនៃសារពើពន្ធសរុប (ខ) ធ្វើសនិទានកម្មលើគោលនយោបាយចំណាយសាធារណ និងការគ្រប់គ្រង (គ) កាត់បន្ថយហានិភ័យនៃទំនុកចិត្តលើមូលនិធិ

សាធារណ និង (ឃ) ធ្វើកំណែទំរង់លើប្រាក់ខែនិងការងារនៅក្នុងរាជការស៊ីវិល ។

ប្រសិទ្ធភាពនៃការចំណាយត្រូវតែបានកែលំអ តាមរយៈការផ្សាភ្ជាប់វាឱ្យកាន់តែជិតស្និទ្ធថែមទៀតទៅនឹងលទ្ធផលអាទិភាព ។ ដើម្បីសំរេចបានគោលដៅកាត់បន្ថយភាពក្រីក្រនេះ រដ្ឋាភិបាលនឹងត្រូវការចាំបាច់ដើម្បីកែលំអគោលដៅ និងផ្ទេរធនធាននានាពីកម្មវិធីនិងវិស័យដែលមិនមែនជាអាទិភាពទៅអោយវិស័យផ្សេងៗដូចជាវិស័យកសិកម្មនិងសុខាភិបាល ដែលចំណាយផ្សេងៗមិនត្រូវបានគេផ្តល់អោយគ្រប់គ្រាន់ដល់អ្នកក្រីក្រ ។

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណ (PEM) ដ៏ទន់ខ្សោយមួយដែលមានយន្តការទទួលខុសត្រូវផ្លូវការនិងក្រៅផ្លូវការតិចតួចមានផលប៉ះពាល់ជាអវិជ្ជមានមួយលើសមត្ថភាពនិងប្រសិទ្ធិភាពនៃការចំណាយលើវិស័យសាធារណ និងលើការកាត់បន្ថយភាពក្រីក្រ ។

ភាពទន់ខ្សោយក្នុងប្រព័ន្ធ PEM ក៏បង្កើតផងដែរនូវកំរិតហានិភ័យលើទំនុកចិត្តខ្ពស់ចំពោះមូលនិធិសាធារណ ។ ប្រព័ន្ធទូទាត់ជាសាច់ប្រាក់គឺជាឧបសគ្គចំបងមួយ ។ ការប្រតិបត្តិថវិកាកាន់តែមានការយឺតយ៉ាវខ្លាំងឡើង និងការបញ្ចេញមូលនិធិមានភាពមិនទៀងទាត់ ។ (សូម្បីតែការបើកប្រាក់ខែក៏មានការយឺតយ៉ាវដែរ រូប ១) ។ ការគ្រប់គ្រងហិរញ្ញវត្ថុដែលមានលក្ខណទន់ខ្សោយក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការបញ្ចេញមូលនិធិដែលបានគ្រោងដោយគ្មានការអនុញ្ញាតិ ដែលបង្កអោយមានហានិភ័យនៃទំនុកចិត្តធ្ងន់ធ្ងរ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ការសើរើនេះផ្តល់អនុសាសន៍ក្នុងការប្រើប្រាស់ប្រព័ន្ធធនាគារដ៏ច្រើនដើម្បីត្រួតពិនិត្យមូលនិធិសាធារណ ត្រួតពិនិត្យប្រព័ន្ធពត៌មានដែលបានកែលំអ និងត្រួតពិនិត្យប្រព័ន្ធគណនីសាធារណដែលបានកែលំអ ។

**រូប១: ការបើកប្រាក់ខែប្រចាំខែនៅក្រសួងសុខាភិបាល ឆ្នាំ២០០១**




នៅពេលជាមួយគ្នានោះដែរ គេមើលឃើញច្បាស់ថា កំណែទំរង់រាជការស៊ីវិល (ផ្តោតលើប្រាក់បៀវត្ស និងការងារ) គឺជាលក្ខខ័ណ្ឌចាំបាច់សំរាប់ការកាត់បន្ថយភាពក្រីក្រ ។ រាជការស៊ីវិលមានបញ្ហាធ្ងន់ធ្ងរដូចជា: ប្រាក់បៀវត្សទាប មានជំនាញទាប ហើយនិងមានសមត្ថភាពទាប ។ កំណែទំរង់រាជការស៊ីវិលដែលមានលក្ខណទូលំទូលាយ នឹងត្រូវបានបង្កើនល្បឿននៅក្នុងរយៈពេលខ្លី ហើយនឹងត្រូវបានអនុវត្តក្នុងរយៈពេលមធ្យម ប្រសិនបើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលត្រូវក្លាយជាការពិត ។

ដោយពិចារណាទៅលើទំហំនៃជំនួយឧបត្ថម្ភពីខាងក្រៅលើចំណាយសរុបរបស់រដ្ឋាភិបាល ការកែលំអការគ្រប់គ្រងជំនួយពីខាងក្រៅដើម្បីធានាដល់ការរៀបចំអាទិភាពនានារបស់រដ្ឋាភិ-បាលក៏មានសារសំខាន់ផងដែរ ។ ទំហំនៃជំនួយឧបត្ថម្ភនេះត្រូវបានដាក់នៅក្រៅថវិកា មានន័យថាការបែងចែកធនធានមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឯកសារថវិការបស់រដ្ឋាភិបាលទេ ហើយមានន័យថាមូលនិធិទាំងនោះមិនត្រូវបានដកចាយតាមរយៈរតនាគារទេ ។

## លទ្ធផល

រាជរដ្ឋាភិបាលកម្ពុជាបានប្រើការវិភាគរបស់ IFAPER ដើម្បីកំណត់អោយបានច្បាស់លាស់នូវគោលដៅនិងចំនុចសំខាន់សំរាប់

NPRS របាយការណ៍ប្រចាំឆ្នាំស្តីពីការរីកចំរើនរបស់ NPRS និងរបៀបវារៈគោលនយោបាយថ្មីរបស់ខ្លួន។ ស្ថាប័នបណ្តុះបណ្តាលនៅក្នុងស្រុករបស់ក្រសួងសេដ្ឋកិច្ចបានប្រើប្រាស់របាយការណ៍នេះសំរាប់បង្រៀន។ ថ្មីៗនេះ នៅខែមេសា ឆ្នាំ២០០៤ សារពត៌មានចាត់ទុកអនុសាសន៍របស់ IFAPER ស្តីអំពីកំណែទំរង់ប្រាក់ខែសំរាប់រាជការស៊ីវិលថាជាការចូលរួមវិភាគទានក្នុងការពិភាក្សាអំពីការបង្កើតរដ្ឋាភិបាលថ្មីមួយ។

រដ្ឋាភិបាលនិងម្ចាស់ជំនួយនានាបានឯកភាពគ្នាលើខ្លឹមសារនិងការកំណត់ពេលវេលាលើអនុសាសន៍សំខាន់ៗនៅក្នុងកំនែទំរង់និងការគ្រប់គ្រងគោលនយោបាយចំណាយសាធារណ។ នៅក្នុងបេសកកម្មបីរួមគ្នារបស់ម្ចាស់ជំនួយ ធនាគារពិភពលោក និងម្ចាស់ជំនួយចំនួន ៩ប្រទេសផ្សេងទៀតបានធ្វើកិច្ចសហប្រតិបត្តិការដើម្បីជួយរាជរដ្ឋាភិបាលក្នុងការកំណត់អាទិភាពនិងរៀបចំវិធានការកែទំរង់នានាតាមលំដាប់លំដោយ។ ពួកគេទាំងអស់គ្នាបានបង្កើតនូវក្របខ័ណ្ឌព្រមព្រៀងគ្នាមួយសំរាប់វាយតំលៃការប្រតិបត្តិ និងយុទ្ធសាស្រ្តសំរាប់គ្រប់គ្រងកំណែទំរង់រចនាសំព័ន្ធចាត់តាំងនិងស្ថាប័នដែលវាមានភាពចាំបាច់ក្នុងការគាំទ្រកម្មវិធីកំណែទំរង់។

ប្រតិបត្តិការនេះបានឈានដល់កិច្ចព្រមព្រៀងគ្នាជាមួយម្ចាស់ជំនួយនានាលើវិធីសាស្រ្តទូទាំងវិស័យ(SWAP)សំរាប់គ្រប់គ្រងចំណាយសាធារណ ផ្អែកលើកិច្ចព្រមព្រៀងស្តីអំពីគោលការណ៍នៃភាពជាដៃគូ លើមូលដ្ឋានសំរាប់ការអនុវត្តរបស់ពួកគេ និងលើការសំរបសំរួលជំនួយ រួមទាំងការបែងចែកធនធាននានា។

## កត្តាជោគជ័យនិងមេរៀនដែលបានរៀនសូត្រ

*សមាហរណកម្មរវាងវិស័យនានានិងក្រុមប្រទេស*

លោក រ៉ប់ប៊ើត តាលីយ៉័រស្សូ ប្រធានក្រុមការងាររបស់ធនាគារពិភពលោកបានមានប្រសាសន៍ថា "យើងបានធ្វើការងារជាច្រើនលើរចនាសំព័ន្ធចំរុះផ្ទៃក្នុង ហើយយើងបានចេញផ្សាយ IFAPER ជារបាយការណ៍ចំរុះមួយ ដែលរួមបញ្ចូលទាំងការវាយតំលៃលើការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់ប្រទេស ការសន្សំពេលវេលាសំរាប់គូសមភាគីរបស់យើង និងធានារាយការណ៍ជូនរដ្ឋាភិបាលជាប្រចាំ"។

ក្រុមស្នូលបានធ្វើការលើជំពូកសំខាន់ៗមុន ទុកអោយក្រុមដែលនៅសេសសល់ពន្យល់ជំពូកដែលទាក់ទងនឹងវិស័យ។ កិច្ចការនេះបូករួមទាំងការបញ្ចូលគ្នាដែលមានលក្ខណៈល្អប្រសើរនៃការអង្កេតលើចំនុចសំខាន់និងការអង្កេតលើវិស័យ។ ក្រុមនេះបានផ្សព្វផ្សាយនូវលទ្ធផលដំបូងនៅក្នុងសិក្ខាសាលាបច្ចេកទេសពីរដែលមានរយៈពេលពីរថ្ងៃដល់រដ្ឋាភិបាល និងម្ចាស់ជំនួយនានាដែលជាប់ពាក់ព័ន្ធ។ ពង្រាងសំយោគមួយដែលបានបញ្ចប់ក្រោយឯកសារសាវតា ត្រូវបានគេលើយកទៅពិភាក្សាយ៉ាងលំអិតជាមួយគូសមភាគីនៅតាមមូលដ្ឋានដែលមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបន្ទាប់មកបានយករបាយការណ៍នេះបញ្ជូនទៅអោយក្រសួងនានា និងបានពិភាក្សាលើអនុសាសន៍ទាំងនោះដែលនឹងត្រូវរក្សាទុកនិងត្រូវអនុវត្ត។ បន្ទាប់មក ធនាគារពិភពលោកបានបញ្ចប់របាយការណ៍នេះ ហើយនិងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយដ៏ធំមួយ ដែលរួមបញ្ចូលទាំងការបង្ហាញរបស់រដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋភិបាល។ សារពត៌មានបានរាយការណ៍យ៉ាងទូលំទូលាយអំពីការពិភាក្សាទាំងនេះ។

*កិច្ចសហប្រតិបត្តិការជាមួយម្ចាស់ជំនួយដទៃទៀត។* នៅពេលដែល SWAPs ត្រូវបានផ្សព្វផ្សាយយ៉ាងត្រឹមត្រូវនៅក្នុងវិស័យអប់រំនិងសុខាភិបាល វិស័យទាំងពីរនេះមានហិរញ្ញវត្ថុសាធារណ

សេចក្តីសង្ខេបនេះរៀបចំដោយ Vera Wilhelm (អ្នកសេដ្ឋវិទូជាន់ខ្ពស់ PRMVP)និង Eve Katz (ទីប្រឹក្សា)។ សំរាប់ពត៌មានបន្ថែមស្តីអំពីរបាយការណ៍នេះ (លេខ ២៩៦១១) សូមទំនាក់ទំនង Robert Taliercio (អ្នកសេដ្ឋវិទូប្រចាំប្រទេស EAS Country Units, PREM Sector Department)តាមលេខ (២០២) ៤៧៣-០០៧១ ឬចូលវិបសាយ **http://prem**.

មិនគ្រប់គ្រាន់។ ធនាគារពិភពលោកបានធ្វើការជាមួយធនាគារ ADB អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ក្រសួងអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស(DFID) គណៈកម្មាការអឺរុប ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ AusAid និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត(SIDA)។ DFID និង SIDA បានផ្តល់នូវហិរញ្ញប្បទានដល់ IFAPER ដែលមានសារប្រយោជន៍សំរាប់រក្សាទុកម្ចាស់ជំនួយដទៃៗទៀត និងសំរាប់បង្កើតការស្រុះស្រួលមតិគ្នា។ ADB និង IMF បានផ្តល់នូវពេលវេលានិងជំនាញសំរាប់បុគ្គលិក។

*ការផ្តល់នូវការណែនាំអំពីការគ្រប់គ្រងផ្លាស់ប្តូរស្ថាប័ន។* រាជរដ្ឋាភិបាលកម្ពុជាដឹងគុណចំពោះជំនួយពីម្ចាស់ជំនួយទាំងអស់ ដែលបានកំណត់អាទិភាព និងរៀបចំវិធានការកែទំរង់តាមលំដាប់លំដោយ ក៏ដូចជាការណែនាំនៅក្នុងផ្នែកកំណែទំរង់ស្ថាប័នផងដែរ។ លោក តាលីយ៉ែរស្សូ បានមានប្រសាសន៍ថា "មិនមែនរបាយការណ៍ទាំងអស់របស់ធនាគារពិភពលោក សុទ្ធតែផ្តល់នូវការណែនាំអំពីការគ្រប់គ្រងផ្លាស់ប្តូរស្ថាប័ននោះទេ ទោះបីជារបាយការណ៍នេះមានសារសំខាន់ក៏ដោយ ក៏កំណែទំរង់ដែលបានផ្តល់អនុសាសន៍នានាត្រូវតែត្រូវបានគេអនុវត្តដែរ"៕

សេចក្តីសង្ខេបនេះរៀបចំដោយ Vera Wilhelm (អ្នកសេដ្ឋវិទូជាន់ខ្ពស់ PRMVP)និង Eve Katz (ទីប្រឹក្សា)។ សំរាប់ពត៌មានបន្ថែមស្តីអំពីរបាយការណ៍នេះ (លេខ ២៥៦១១) សូមទំនាក់ទំនង Robert Taliercio (អ្នកសេដ្ឋវិទូប្រចាំប្រទេស EAS Country Units, PREM Sector Department)តាមលេខ (២០២) ៤៧៣-០០៧១ ឬចូលវិបសាយ http://prem.